# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/៧១៤៧

## ស្តីពី

## ការកែសម្រួលមាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៥៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា២ .- ថ្មី**

**អ.ជ.ប.គ.ញ**. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- ឧបនាយករដ្ឋមន្ត្រី ១រូប | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីការពារជាតិ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |

៥- ឥស្សរជនជាន់ខ្ពស់របស់រាជរដ្ឋាភិបាលឬទេសរដ្ឋមន្ត្រី ១រូប អនុប្រធានប្រចាំការ
៦- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
៧- រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក
៨- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សមាជិក
៩- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១០- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
១១- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
១២- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
១៣- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក
១៤- អគ្គស្នងការនគរបាលជាតិ សមាជិក
១៥- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៦- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
១៧- អគ្គលេខាធិការ **អ.ជ.ប.គ.ញ.** សមាជិក។

អនុប្រធានប្រចាំការ **អ.ជ.ប.គ.ញ.** ទទួលបន្ទុកលើការងាររបស់អគ្គលេខាធិការដ្ឋាន **អ.ជ.ប.គ.ញ.**។ **អ.ជ.ប.គ.ញ.** អាចបន្ថែមសមាសភាពជាអនុប្រធាននិងសមាជិកតាមការចាំបាច់ ដោយអនុក្រឹត្យ។ សមាសភាពជាក់ស្តែងរបស់ **អ.ជ.ប.គ.ញ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរស. ២៣០៩. ៤១៦

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**